បេឡាជាតិសន្តិសុខសង្គម

National Social Security Fund

# បទបង្ហាញស្តីពី
# ការអនុវត្តរបបសន្តិសុខសង្គម




ប្រអប់បណ្ដឹងអនាមិក
ប្រអប់បណ្ដឹងអនាមិក

# មាតិកា

សាវតារបេឡាជាតិសន្តិសុខសង្គម

ក. ក្របខណ្ឌគោលនយោបាយ

ខ. បច្ចុប្បន្នភាពនៃការអនុវត្ត និងសមិទ្ធផល

គ. ការអនុវត្តរបបសន្តិសុខសង្គម

ឃ. សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

# សាវតាបេឡាជាតិសន្តិសុខសង្គម

**បេឡាជាតិសន្តិសុខសង្គម** ដែលហៅកាត់ថា **ប.ស.ស.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមអាណាព្យាបាល បច្ចេកទេស គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. មានសមាសភាពត្រីភាគី៖

- តំណាងភាគីរាជរដ្ឋាភិបាល
- តំណាងភាគីនិយោជក
- តំណាងសមាជិក ប.ស.ស. (ភាគីកម្មករនិយោជិត)។

❖ ចាប់ផ្តើមបង្កើតឡើងនៅ ឆ្នាំ២០០៧ និងចាប់ផ្តើមអនុវត្តទៅរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់បងប្អូនកម្មករនិយោជិត នៅឆ្នាំ២០០៨

## ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

សហគ្រាសថ្មីដែលទើបបង្កើតត្រូវមានកាតព្វកិច្ចមកចុះបញ្ជីនៅប.ស.ស. ក្នុងរយៈពេល ៣០ ថ្ងៃ

## ការបង់ភាគទាន

| | | |
|---|---|---|
| ផ្នែកហានិភ័យការងារ | និយោជកបង់ | ០,៨% |
| ផ្នែកថែទាំសុខភាព | និយោជកបង់ | ២,៦% |
| ផ្នែកប្រាក់សោធន | និយោជក+កម្មករនិយោជិត | ៤% → ក្នុងរយៈពេល ៥ឆ្នាំដំបូង |

នៃប្រាក់ឈ្នួលជាប់ភាគទាន ទាបបំផុត ៤០០,០០០រៀល និងខ្ពស់បំផុត ១,២០០,០០០រៀល

# ក ក្របខណ្ឌគោលនយោបាយ



យុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១



ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា



ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០២៤-២០៣៥



ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល (UHC) ២០២៤-២០៣៥

# ២ បច្ចុប្បន្នភាពនៃការអនុវត្ត និងសមិទ្ធផល

## ២.១. លិខិតបទដ្ឋានគតិយុត្ត



# ២ បច្ចុប្បន្នភាពនៃការអនុវត្ត និងសមិទ្ធផល

## ២.២. ការពង្រីកវិសាលភាពគ្របដណ្តប់

**វិស័យឯកជន**

បុគ្គលធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាន (បុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ)

- ឆ្នាំ២០០៨ អនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ
- ឆ្នាំ២០១៦ អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ឆ្នាំ២០២២ អនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន



# ២ បច្ចុប្បន្នភាពនៃការអនុវត្ត និងសមិទ្ធផល

## ២.២. ការពង្រីកវិសាលភាពគ្របដណ្ដប់ (ត)



វិស័យសាធារណៈ

មន្ត្រីសាធារណៈ

អតីតមន្ត្រីសាធារណៈ
អតីតយុទ្ធជន



- ឆ្នាំ២០១៨ អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ឆ្នាំ២០២១ អនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

# ខ បច្ចុប្បន្នភាពនៃការអនុវត្ត និងសមិទ្ធផល

## ខ.២. ការពង្រីកវិសាលភាពគ្របដណ្តប់ (ត)



បុគ្គលស្វ័យនិយោជន៍

អ្នកក្នុងបន្ទុកសមាជិក



[សហព័ន្ធ (ប្ដី ឬប្រពន្ធ) និងកូន]

ឆ្នាំ២០២៣ អនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស.

គ ការអនុវត្តរបបសន្តិសុខសង្គម

១. និយមន័យហានិភ័យការងារ( គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ)

២. តាវកាលិក( អត្ថប្រយោជន៍ )

៣. ការទទួលបានធនលាភឧត្តរជីវី និងការផុតរលត់ការទទួលបានធនលាភឧត្តរជីវី (ករណីសមាជិក ប.ស.ស. ស្លាប់ដោយសារគ្រោះថ្នាក់ការងារ)

# ១. ហានិភ័យការងារ (គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ)

## តើអ្វីជាហានិភ័យការងារ?

- ហានិភ័យការងារ សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងដោយ ឥតគ្រោងទុកបណ្តាលមកពីគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។



គ្រោះថ្នាក់នៅកន្លែងការងារ (ពេលកំពុងបំពេញការងារ)



គ្រោះថ្នាក់ពេលកំពុងធ្វើដំណើរ ទាំងទៅទាំងមក ដោយមិនវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន។



ជំងឺវិជ្ជាជីវៈ ជាជំងឺកើតឡើងពីមុខរបរប្រើកម្លាំង មុខរបរប៉ះពាល់ជាតិពុល មុខរបរក្នុងលក្ខខណ្ឌមិនប្រក្រតី។

**ចំណាំ៖ ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយចេតនាផ្ទាល់ខ្លួនមិនត្រូវទទួលបានតាវកាលិកផ្នែកហានិភ័យការងារទេ។**

# ២. គាថាភាលិក (អត្ថប្រយោជន៍)

១. ផ្តល់សេវាសង្គ្រោះបន្ទាន់

២. ផ្តល់សេវាថែទាំ និងព្យាបាល (ព្យាបាលរហូតដល់ជាសះស្បើយ)

- ចូលមន្ទីរពេទ្យជាដៃគូ (មិនអស់លុយ)
- ចូលមន្ទីរពេទ្យមិនមែនជាដៃគូ(ជនរងគ្រោះត្រូវចេញលុយមុនរួចស្នើសុំទូទាត់ពី ប.ស.ស. ទូទាត់សងតាមតម្លៃមន្ទីរពេទ្យជាដៃគូ ទទួលស្គាល់ដោយ ប.ស.ស.)

៣. ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

- ផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃជាប់ភាគទាន ជូនជនរងគ្រោះសម្រាប់ថ្ងៃអាក់ខានការងារចាប់ពីថ្ងៃទី២ ឡើងទៅ
- ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់អ្នកមើលថែទាំជនរងគ្រោះក្នុងពេលសម្រាកនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ស្មើនឹង ៥០% នៃប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% របស់ជនរងគ្រោះ (មានលិខិតបញ្ជាក់ពីពេទ្យ)។

# ការគណនាប្រាក់បំណាច់ប្រចាំថ្ងៃ

| ខែ | ប្រាក់ឈ្នួលសរុប | ប្រាក់ឈ្នួលជាប់ភាគទាន | ប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំខែ | ប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃ | ប្រាក់ឈ្នួលជាប់ភាគទានប្រចាំថ្ងៃ ៧០% | ប្រាក់បំណាច់ប្រចាំថ្ងៃ៧០% នៃប្រាក់ឈ្នួលជាប់ភាគទាន ៩០ថ្ងៃ |
|---|---|---|---|---|---|---|
| មករា | ៨៥០ ០០០៛ | ៨៥០ ០០០៛ | ១ ០០០ ០១៧៛ | ៣៣ ៣៣៤៛ | ២៣ ៣៣៤៛ | ២ ១០០ ០៣៥៛ |
| កុម្ភៈ | ៨៥០ ១០០៛ | ៨៥០ ១០០៛ | | | | |
| មីនា | ៩៥០ ០០០៛ | ៩៥០ ០០០៛ | | | | |
| មេសា | ៩៥០ ០០០៛ | ៩៥០ ០០០៛ | | | | |
| ឧសភា | ១ ២០០ ០០០៛ | ១ ២០០ ០០០៛ | | | | |
| មិថុនា | ១ ៣០០ ០០០៛ | ១ ២០០ ០០០៛ | | | | |
| | សរុប | ៦ ០០០ ១០០៛ | | | | |

ជំហានទី១ គណនាប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំខែ (រយៈពេល ៦ខែចុងក្រោយ)

៦ ០០០ ១០០៛ / ៦ខែ = ១ ០០០ ០១៧៛

ជំហានទី២ គណនាប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃ

១ ០០០ ០១៧៛ / ៣០ថ្ងៃ = ៣៣ ៣៣៤៛

ជំហានទី៣ គណនាប្រាក់ឈ្នួលជាប់ភាគទានប្រចាំថ្ងៃ ៧០%

$$\frac{៣៣\ ៣៣៤៛ \times ៧០}{១០០} = ២៣\ ៣៣៤៛$$



បសស

# ៤. ករណីគ្រោះថ្នាក់រហូតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

➢ សំដៅលើការបាត់បងអវយវៈ ឬខូចទ្រង់ទាយដើមនៃសេរីរាង្គ ក្រោយពេលទទួលរងហានិភ័យការងារ (គ្រោះថ្នាក់ការងារ)

ក. កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្រោម ២០%ផ្តល់ប្រាក់វិភាជន៍ (បើកផ្តាច់)

ខ. កម្រិតបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ចាប់ពី ២០%ឡើង ផ្តល់ប្រាក់ធនលាភដល់ជនរងគ្រោះ ១ខែម្តង (ផ្តល់ជូនអ្នកចាំថែរក្សា ៥០%នៃប្រាក់ធនលាភរបស់ជនរងគ្រោះ មានការបញ្ជាក់ពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស.)

**៥. ផ្តល់សេវាស្តារនីតិសម្បទា** កម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារបណ្តាលឲ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍៖

ក. មានសិទ្ធិទទួលបានសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រ(ឧបករណ៍សិប្បនិម្មិត)

ខ. មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ

គ. មានសិទ្ធិទទួលបានសេវាសង្គម





# ៦. ករណីបាត់បង់ជីវិត

- ✓ ផ្តល់សោហ៊ុយដឹកជញ្ជូនសពរហូតដល់ផ្ទះជនរងគ្រោះ
- ✓ ផ្តល់ប្រាក់វិភាជន៍បូជាសព ១០,០០០,០០០ រៀល (១០លានរៀល) មានសិទ្ធិទាមទាររយៈពេល១ឆ្នាំ

  - បណ្ណសមាជិក ប.ស.ស. របស់មរណជន
  - សេចក្តីចម្លងសំបុត្រមរណភាព
  - អត្តសញ្ញាបណ្ណរបស់សិទ្ធិវន្ត ឬអ្នកចាត់ចែងបូជាសព
  - គណនីធនាគារដៃគូដែលកំណត់ដោយ ប.ស.ស.
  - ឯកសារចាំបាច់ផ្សេងៗទៀតតាមការចាំបាច់របស់ ប.ស.ស.។

# ៣.សិទ្ធិនៃការទទួលបានធនលាភឧត្តរជីវី និងការផុតរលត់ការទទួលបានធនលាភឧត្តរជីវី

❖ <u>ករណីនៅលីវ</u>

-ឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់របស់ ជនរងគ្រោះ ដែលមានអាយុយ៉ាងតិច៦០ឆ្នាំ និងមិនប្រកបមុខរបរដែលមានប្រាក់ចំណូលឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព ត្រូវមានឈ្មោះនៅក្នុងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ។

- ចំពោះឪពុកម្ដាយ ឬមនុស្សចាស់ជរាដែលមានជំងឺរ៉ាំរ៉ៃ ព្យាបាលមិនជា ឬមានទុព្វលភាព និងមិនមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព មិនត្រូវកំណត់អាយុឡើយ។









## ❖ ករណីរៀបអាពាហ៍ពិពាហ៍ (មានសំបុត្រអាពាហ៍ពិពាហ៍)

❑ ករណីសហព័ទ្ធ (ប្ដីប្រពន្ធ)

- ប្ដី ឬប្រពន្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទនៃហានិភ័យការងារ ឬមុនពេលទទួលមរណភាពដោយហានិភ័យការងារ



## ❖ ករណីរៀបអាពាហ៍ពិពាហ៍ (គ្មានសំបុត្រអាពាហ៍ពិពាហ៍)

**ករណីសហព័ទ្ធ** ប្ដីឬប្រពន្ធមិនទទួលបានអត្ថប្រយោជន៍ពី ប.ស.ស. ឡើយ

**ករណីឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់ ទទួលបានដូចករណីនៅលីវ។**



បសស បសស បសស

## ❑ <u>ករណីកូន</u> ឪពុក ម្ដាយ ទោះបីជាមាន ឬគ្មានសំបុត្រអាពាហ៍ពិពាហ៍ មានសិទ្ធទទួលបានដូចគ្នា



- ជាកូនបង្កើត
- កូនមិនទាន់រៀបអាពាហ៍ពិពាហ៍
- មានអាយុមិនលើសពី២១ឆ្នាំ




កូនសុំរបស់សាមីជនរងគ្រោះដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនរងគ្រោះ



ករណីកូនពិការ ឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារ ឬមុខរបរ ដែលមានប្រាក់ចំណូលត្រូវផ្ដល់ធនលាភ ឧត្តរជីវីអស់មួយជីវិត។ (បញ្ជាក់ពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស.)




ក្នុងករណីលែងលះ ឬករណីមរណភាពនៃប្ដី ឬប្រពន្ធ កូននៃគូស្រករក្រោយដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍មុនដែរ

## ❖ សិទ្ធិនៃការផុតរលត់ទទួលបានធនលាភឧត្តរជីវី

- ➢ នៅពេលដែលសាមីជនទទួលមរណភាព (ឪពុក ម្ដាយ ជនចាស់ជរានៅក្នុងបន្ទុក)
- ➢ នៅពេលដែលសាមីជន(ប្ដីឬប្រពន្ធ)រៀបអាពាហ៍ពិពាហ៍ជាថ្មី ករណីនេះសាមីជនត្រូវជូនដំណឹងមក ប.ស.ស. យ៉ាងយូរ ៣០ថ្ងៃ បន្ទាប់ពីចុះសំបុត្រអាពាហ៍ពិពាហ៍ថ្មី។



# គ ការអនុវត្តរបបសន្តិសុខសង្គម

ប.ស.ស. ថែទាំសុខភាព

១. លក្ខខណ្ឌ និងសិទ្ធិទទួលបានសេវាព្យាបាលថែទាំសុខភាព

២.តាមការលិក ( អត្ថប្រយោជន៍ )

៣. បែបបទ និងនីតិវិធីទៅទទួលសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ

# ១. លក្ខខណ្ឌ និងសិទ្ធិទទួលបានសេវាព្យាបាលថែទាំសុខភាព

**ដើម្បីទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សមាជិកប.ស.ស. ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖**

- បានចុះបញ្ជីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថាន និងមានប័ណ្ណសមាជិក ប.ស.ស. និងបានបង់ភាគទាន ២(ពីរ) ខែជាប់គ្នា
- នៅពេលសមាជិក ត្រូវបានបង់ភាគទាន ២(ពីរ)ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទាន សមាជិកនៅមានសិទ្ធិទទួលរយៈពេល ២(ពីរ)ខែ បន្តទៀត
- ករណីសមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះដែលមានសិទ្ធិទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងបានដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាល អាចមានទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្ររហូតដល់កាលបរិច្ឆេទសម្រាលកូន។

# ២. តាវកាលិក (អត្ថប្រយោជន៍)

១ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

២ ផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ

៣ វិភាជន៍បូជាសព (ប្រាក់បូជាសព)

# ១ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ





- សេវាពិគ្រោះជំងឺក្រៅ
- ការព្យាបាលដោយសម្រាកនៅមន្ទីរពេទ្យ



- សេវាសង្គ្រោះបន្ទាន់



- សេវាព្យាបាលដោយស្ពំ និងដោយចលនា





- សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និងក្រោយសម្រាលកូន





- សេវាស្តារនីតិសម្បទា



- ជំងឺរ៉ាំរ៉ៃ (ផ្តល់តែឱសថសារវន្ត)

# ❖ ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

សម្រាប់បុគ្គលិកប.ស.ស
ឈ្មោះ:..............ហ៊ិន.គីមហ៊ន.............
..................ភ្នំពេញ.ថ្ងៃទី..២៨.ខែ.កក្កដា...ឆ្នាំ.២០២៤
ហត្ថលេខា

**ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភ**
**កម្មករនិយោជិត មន្ត្រីរាជការ មន្ត្រីកម្មសិក្សា មន្ត្រីជាប់កិច្ចសន្យាជាស្ត្រី**
**មុនពេលសម្រាល ក្រោយពេលសម្រាលនិងកូនទទួលថ្នាំបង្ការ**

**១.ឈ្មោះសហគ្រាសគ្រឹះស្ថានឬស្ថាប័ន**.....ធីនើ.ហ្វេស៊ិន.(ខេមបូឌា)..........

**២.លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថានឬស្ថាប័ន** | 1 | 0 | 0 | 4 | 0 | 6 | 1 | 8 |

**៣.សមាជិក** ☑ កម្មករនិយោជិត ☐ មន្ត្រីរាជការ ☐ មន្ត្រីកម្មសិក្សា ☐ មន្ត្រីជាប់កិច្ចសន្យា ☐ ស្ត្រីមានបណ្ណម.ស.ស.

- ឈ្មោះសមាជិកប.ស.ស./ម.ស.ស. ..................................ស៊ិន.ផាន់ណា..........
- ឈ្មោះបណ្ណសមាជិកប.ស.ស./បណ្ណម.ស.ស. | 2 | 8 | 5 | 0 | 1 | 1 | 5 | 0 | 0 | 0 | 0 | 2 | 5 | 5 | 8 |
- អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ផ្ទះលេខ 77.1T.... ផ្លូវ28......... សង្កាត់/ឃុំ ..បឹងកក់ទី.១..... ខណ្ឌ/ស្រុក/ក្រុង ....ទួលគោក......... រាជធានី/ខេត្ត ...ភ្នំពេញ.........
- លេខទូរស័ព្ទ៖..078521135..........

| ល.រ | ប្រភេទសេវា | កាលបរិច្ឆេទចាប់ផ្តើម | កាលបរិច្ឆេទបញ្ចប់ |
|---|---|---|---|
| 1 | គត៌មានអាយុតិចជាង១២សប្តាហ៍ | 07/06/2024 | 30/08/2024 |
| 2 | គត៌មានអាយុ២០ទៅ២៤សប្តាហ៍ | 25/10/2024 | 22/11/2024 |
| 3 | គត៌មានអាយុ៣០ទៅ៣២សប្តាហ៍ | 03/01/2025 | 17/01/2025 |
| 4 | គត៌មានអាយុ៣៦ទៅ៣៨សប្តាហ៍ | 14/02/2025 | 28/02/2025 |

**៦.ឯកសារភ្ជាប់**

- បណ្ណសមាជិកប.ស.ស./បណ្ណម.ស.ស.
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សៀវភៅសុខភាពមាតា
- បណ្ណសុខភាពកុមារ
- សេចក្តីចម្លងសំបុត្រកំណើត

ថ្ងៃពុធ ៦ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤
**ស្នាមមេដៃ និងឈ្មោះសាមីជន**

---

ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

សម្រាប់បុគ្គលិកប.ស.ស
ឈ្មោះ:..............ស៊ុម.សុជាតិ.............
..................ភ្នំពេញ.ថ្ងៃទី....៨...ខែ.សីហា...ឆ្នាំ.២០២៣
ហត្ថលេខា

**ទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភ**
**កម្មករនិយោជិត មន្ត្រីរាជការ មន្ត្រីកម្មសិក្សា មន្ត្រីជាប់កិច្ចសន្យាជាស្ត្រី**
**មុនពេលសម្រាល ក្រោយពេលសម្រាលនិងកូនទទួលថ្នាំបង្ការ**

**១.ឈ្មោះសហគ្រាសគ្រឹះស្ថានឬស្ថាប័ន**....ម៉េង.អៀង.ហ្គាមេន.ហ្វេកតរី..........

**២.លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថានឬស្ថាប័ន** | 1 | 0 | 0 | 0 | 1 | 4 | 5 | 8 |

**៣.សមាជិក** ☑ កម្មករនិយោជិត ☐ មន្ត្រីរាជការ ☐ មន្ត្រីកម្មសិក្សា ☐ មន្ត្រីជាប់កិច្ចសន្យា ☐ ស្ត្រីមានបណ្ណម.ស.ស.

- ឈ្មោះសមាជិកប.ស.ស./ម.ស.ស. ..................................វ៉េន.សុខឿន..........
- ឈ្មោះបណ្ណសមាជិកប.ស.ស./បណ្ណម.ស.ស. | 2 | 8 | 8 | 0 | 1 | 1 | 5 | 0 | 0 | 0 | 0 | 2 | 2 | 2 | ឡ |
- អាសយដ្ឋានអចិន្ត្រៃយ៍ ៖ ផ្ទះលេខ ............ ផ្លូវ ............ សង្កាត់/ឃុំ ....ឫស្សីកែវ....... ខណ្ឌ/ស្រុក/ក្រុង ....ឫស្សីកែវ......... រាជធានី/ខេត្ត ...ភ្នំពេញ.........
- លេខទូរស័ព្ទ៖..015957253..........

| ល.រ | ប្រភេទសេវា | កាលបរិច្ឆេទចាប់ផ្តើម | កាលបរិច្ឆេទបញ្ចប់ |
|---|---|---|---|
| 1 | ថ្ងៃទី៧ក្រោយសម្រាល (ពិនិត្យទាំងម្តាយទាំងកូន) | 09/06/2023 | 12/06/2023 |
| 2 | ថ្ងៃទី១៤ក្រោយសម្រាល (ពិនិត្យទាំងម្តាយទាំងកូន) | 16/06/2023 | 19/06/2023 |
| 3 | កូនមានអាយុ១ខែកន្លះ (ពិនិត្យទាំងម្តាយទាំងកូន) | 17/07/2023 | 20/07/2023 |
| 4 | កូនមានអាយុ២ខែកន្លះ (ពិនិត្យសុខភាពកូន) | 17/08/2023 | 24/08/2023 |
| 5 | កូនមានអាយុ៣ខែកន្លះ (ពិនិត្យសុខភាពកូន) | 17/09/2023 | 24/09/2023 |
| 6 | កូនមានអាយុ៦ខែ (ពិនិត្យសុខភាពកូន) | 02/12/2023 | 09/12/2023 |
| 7 | កូនមានអាយុ៩ខែ (ពិនិត្យសុខភាពកូន) | 02/03/2024 | 09/03/2024 |
| 8 | កូនមានអាយុ១២ខែ (ពិនិត្យសុខភាពកូន) | 02/06/2024 | 09/06/2024 |
| 9 | កូនមានអាយុ១៨ខែ (ពិនិត្យសុខភាពកូន) | 02/12/2024 | 09/12/2024 |
| 10 | កូនមានអាយុ២៤ខែ (ពិនិត្យសុខភាពកូន) | 02/06/2025 | 09/06/2025 |

**៦.ឯកសារភ្ជាប់**

- បណ្ណសមាជិកប.ស.ស./បណ្ណម.ស.ស.
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សៀវភៅសុខភាពមាតា
- បណ្ណសុខភាពកុមារ
- សេចក្តីចម្លងសំបុត្រកំណើត

ថ្ងៃពុធ ៦ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤
**ស្នាមមេដៃ និងឈ្មោះសាមីជន**

## ➢ សេវាបង្ការសុខភាព

១-សេវាចាក់វ៉ាក់សាំងជំងឺឆ្កែឆ្កួត

២-សេវាចាក់សេរ៉ូមប្រឆាំងជំងឺឆ្កែឆ្កួត

៣-សេវាចាក់សេរ៉ូមប្រឆាំងជំងឺតេតាណូស

៤-សេវាចាក់សេរ៉ូមប្រឆាំងពិសពស់

៥-សេវាពិនិត្យឈាមរកជំងឺពក ក មាន ៖ TSH (Thyroid Stimulating Hormine) និង Free T3 (Free Triiodothyronine) Free T4 (Free Thyroxine)

៦-សេវាពិនិត្យឈាមកំណត់អបោធាតុមហារីកក្រោយការព្យាបាលជំងឺមហារីកដោយវះកាត់ និង/ឬ ក្រោយការព្យាបាលជំងឺមហារីកដោយចាក់គីមី និង/ឬ ក្រោយការព្យាបាល ជំងឺមហារីកដោយបាញ់កាំរស្មីអ៊ិចមាន៖ CA15-3 (Cancer Antigen15-3), CA19-9 (Cancer Antigen 19-9), Ca125 (Cancer Antigen 125), PSA (Prostate-Specific Antigen), HCG (Beta-Human Chorionic Gonadotropin)

- ❖ សេវាបង្ការខាងលើនេះត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ ឬ វិទ្យាស្ថានសាធារណៈ។
- ❖ សេវានេះមិនត្រូវបានទូទាត់សងវិញចំពោះការប្រើប្រាស់សេវានៅមូលដ្ឋាន សុខាភិបាលឯកជន ឬមន្ទីរពិសោធន៍ឯកជនក្នុង ឬក្រៅប្រទេសឡើយ លើកលែងតែមានការអនុញ្ញាតជាមុនពីបេឡាជាតិសន្តិសុខសង្គម។

## គ. ប្រភេទជំងឺរ៉ាំរ៉ៃ

យោងមាត្រា១៦នៃប្រកាសលេខ២៣៥/២៤អនក្រ.បក ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ប្រភេទជំងឺរ៉ាំរ៉ៃក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានជាកាតព្វកិច្ចមានដូចជា៖

១-ជំងឺខ្សោយបេះដូង (Cardiac Failure)

២-ជំងឺសាច់ដុំបេះដូង (Cardiomyopathy)

៣-ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)

៤-ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)

៥-ជំងឺតំរងនោមរ៉ាំរ៉ៃ (Chronic renal disease)

៦-ជំងឺក្រិនថ្លើម (Cirrhosis of the liver)

៧-ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)

៨-ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)

៩-ជំងឺក្រិនសរីរាង្គ(Multiple Sclerosis)

១០-ជំងឺវិកលចរិត( Schizophrenia)

១១-ជំងឺលុយពុស (Systemic Lupus Erythematosus)

១២-ជំងឺតាឡាសសីមី(Thalassemia)



# ២ ប្រាក់បំណាច់ប្រចាំថ្ងៃ



**ផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃពេលមានជំងឺ**

- ប្រាក់បំណាច់ប្រចាំថ្ងៃ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃជាប់ភាគទានរបស់សាមីជន
- បង់ភាគទាន២ខែជាប់គ្នា ឬ ៦/១២ គិតមកដល់ខែមានបញ្ហាសុខភាព
- អាក់ខានការងារចាប់ពីថ្ងៃទី៨ ឡើងទៅ ដោយសារការសម្រាកព្យាបាលថែទាំជំងឺ ឬរបួសតាមវេជ្ជបញ្ជានៅក្នុងមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.



**ផ្តល់ប្រាក់បំណាច់សម្រាលមាតុភាព**

- បង់ភាគទានយ៉ាងតិច៩ខែ/១២ខែ
- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃជាប់ភាគទានរបស់សាមីជនចំនួន ៩០ថ្ងៃ

## ៣ វិភាជន៍បូជាសព (ប្រាក់បូជាសព)

**<u>ករណីបាត់បង់ជីវិត</u>**

- ✓ ផ្តល់ប្រាក់វិភាជន៍បូជាសព ២,000,000 រៀល (២លានរៀល)
  មានសិទ្ធិទាមទាររយៈពេល១ឆ្នាំ
- ✓ ទម្រង់ទាមទារវិភាជន៍បូជាសពត្រូវភ្ជាប់មកជាមួយនូវ៖
  - បណ្ណសមាជិក ប.ស.ស. របស់មរណជន
  - សេចក្តីចម្លងសំបុត្រមរណភាព
  - អត្តសញ្ញាបណ្ណរបស់សិទ្ធិវន្ត ឬអ្នកចាត់ចែងបូជាសព
  - គណនីធនាគារដៃគូដែលកំណត់ដោយ ប.ស.ស.
  - ឯកសារចាំបាច់ផ្សេងៗទៀតតាមការចាំបាច់របស់ ប.ស.ស.។



បសស បសស បសស

# សេវាខាងក្រោមនេះ មិនផ្តល់ជូនសមាជិក ប.ស.ស. មានដូចជា:

- ការព្យាបាលទាំងឡាយណាដែលមិនគិតថ្លៃចែងក្នុងគោលនយោបាយសុខាភិបាល សាធារណៈ
- ការថែទាំធ្មេញ (ការសម្អាត ការប៉ះ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬវះកាត់ដើម្បីកែសម្ផស្ស
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលការអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
- ការលាងឈាម
- ការត្រួតពិនិត្យសុខភាពទូទៅ

# ៣. បែបបទ និងនីតិវិធីទៅទទួលសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ

**មុនទៅប្រើប្រាស់សេវា**








**កំពុងប្រើប្រាស់សេវា**





**ពេលប្រើប្រាស់សេវាចប់**




ប្រអប់បណ្ដឹងអនាមិក

❖ ក្នុងករណីបើខាងមន្ទីរពេទ្យឲ្យបង់ប្រាក់ ឬត្រូវការបោះត្រាលើឯកសារផ្សេងៗ ឬមានបញ្ហាកើតឡើងផ្សេងៗ សូមទាក់ទងទៅភ្នាក់ងារ ប.ស.ស. នៅទីនោះផ្ទាល់ ឬCall ១២៨៦/១២៩៧ ឬមន្ត្រីតាមបណ្ដាសាខា ប.ស.ស. ខេត្ត/ក្រុង/ស្រុក/ខណ្ឌ។

តើអ្វីទៅជាការទទួល និងផ្តល់សេវាត្រឹមត្រូវរវាងសមាជិក ប.ស.ស. និងគ្រូពេទ្យព្យាបាល?

ប្រាកដណាស់! គ្រប់សមាជិក ប.ស.ស. ត្រូវតែទទួលបានសេវាដូចខាងក្រោម៖

- ❖ សមាជិក ប.ស.ស. ត្រូវតែទទួលបានការពិគ្រោះ និងពិនិត្យជំងឺត្រឹមត្រូវពីគ្រូពេទ្យព្យាបាល មុនពេលគ្រូពេទ្យចេញវេជ្ជបញ្ជាឱ្យបើកថ្នាំ
- ❖ សមាជិក ប.ស.ស. ទាំងអស់មិនត្រូវទទួលថ្នាំ ឬទទួលទានថ្នាំ ដោយមិនទាន់បានពិគ្រោះ និងពិនិត្យជំងឺត្រឹមត្រូវពីគ្រូពេទ្យព្យាបាលនោះឡើយ
- ❖ សមាជិក ប.ស.ស. ត្រូវហ៊ានសួរទៅកាន់គ្រូពេទ្យ ពេលគ្រូពេទ្យបើកផ្តល់ថ្នាំដោយមិនបានពិគ្រោះ ឬពិនិត្យជំងឺត្រឹមត្រូវ
- ❖ គ្រូពេទ្យព្យាបាល ត្រូវផ្តល់ការព្យាបាលត្រឹមត្រូវជូនសមាជិក ប.ស.ស. ស្របទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់គ្រូពេទ្យដែលបានដាក់ចេញដោយក្រសួងសុខាភិបាល
- ❖ គ្រូពេទ្យព្យាបាល ត្រូវណែនាំសមាជិក ប.ស.ស. ដែលត្រូវទទួលសេវា ឱ្យបានយល់ច្បាស់ពីសិទ្ធិទទួលបានសេវាប្រកបដោយភាពត្រឹមត្រូវ
- ❖ គ្រូពេទ្យព្យាបាល មិនត្រូវបើកថ្នាំឱ្យសមាជិក ប.ស.ស. ដោយមិនបានពិគ្រោះ និងពិនិត្យព្យាបាលជំងឺឡើយ



បសស បសស បសស

✍ <u>បញ្ជាក់៖ ក្នុងករណីរកឃើញថា សមាជិក ប.ស.ស. និងគ្រូពេទ្យព្យាបាល បានសមគំនិតគ្នាដោយចេតនា ក្នុងគោលបំណងកេងចំណេញផលប្រយោជន៍ណាមួយពី ប.ស.ស. នោះ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងអនុវត្តវិធានការរួមមាន៖</u>

- សម្រាប់សមាជិក ប.ស.ស. នឹងត្រូវលុបឈ្មោះចេញពី ប.ស.ស. ដោយមិនអនុញ្ញាតឱ្យបន្តប្រើប្រាស់សេវា ប.ស.ស. បន្តទៀតឡើយ និងត្រូវសងត្រឡប់មកវិញនូវទឹកប្រាក់ដែលបានកេងចំណេញស្របទៅតាមការខាតបង់របស់មូលនិធិសន្តិសុខសង្គម
- ដោយឡែកសម្រាប់មូលដ្ឋានសុខាភិបាលដៃគូ នឹងត្រូវផ្តាច់កិច្ចព្រមព្រៀងជាមួយ ប.ស.ស. ដោយមិនអនុញ្ញាតឱ្យបន្តផ្តល់សេវាជូនសមាជិក ប.ស.ស. ទៀតឡើយ និងត្រូវសងត្រឡប់មកវិញនូវទឹកប្រាក់ដែលបានកេងចំណេញស្របទៅតាមការខាតបង់របស់មូលនិធិសន្តិសុខសង្គម
- ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

# គ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

១.គោលការណ៍សន្តិសុខសង្គម

២.អត្រាភាគទាន

៣.សោធនជរាភាព

៤.សោធនទុព្វលភាព

៥.វិភាជន៍បូជាសព(ប្រាក់បូជាសព)និងសោធនឧត្តរជីវី

៦.លក្ខខណ្ឌចូលរួមតាមរបបភាគទានដោយស្ម័គ្រចិត្ត។

ប.ស.ស.
ប្រាក់សោធន

# ១.គោលការណ៍សន្តិសុខសង្គមផ្នែកប្រាក់សោធន

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនបង្កើតឡើងដើម្បី៖

- ធានាឲ្យមានសមធម៌ និងសាមគ្គីធម៌សង្គម
- ធានាសន្តិសុខ និងស្ថេរភាពប្រាក់ចំណូលនៅពេលសមាជិក **ប.ស.ស**. ចូលនិវត្តន៍
- ទទួលបានសេវាធានារ៉ាប់រងសុខភាពនៅពេលសមាជិក **ប.ស.ស**. ចូលនិវត្តន៍
- អ្នកនៅក្នុងបន្ទុកអាចទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ នៅពេលអ្នកចូលនិវត្តន៍ទទួលមរណភាព
- អ្នកក្នុងបន្ទុកឬអ្នកចាត់ចែងបូជាសពអាចទទួលបានប្រាក់សម្រាប់បូជាសពនៅពេលអ្នកចូលនិវត្តន៍មរណភាព
- រួមចំណែកការពារសិទ្ធិ សេរីភាពចំពោះមនុស្សវ័យចាស់។

# ២. អត្រាភាគទាន

| ឆ្នាំ | អត្រាភាគទាន | កាលបរិច្ឆេទ | កម្មករនិយោជិត | និយោជក | ប្រាក់ឈ្នួលពិតាន |
|---|---|---|---|---|---|
| ៥ឆ្នាំដំបូង | ៤% | ១០/២២-៩/២៧ | ២%<br>(២៤,០០០រៀល) ក្នុង១ខែ | ២%<br>(២៤,០០០រៀល)ក្នុង១ខែ | ១,២០០,០០០រៀល |
| ៥ឆ្នាំបន្ទាប់ | ៨% | ១០/២៧-៩/៣២ | ៤%<br>(៤៨,០០០រៀល)ក្នុង១ខែ | ៤%<br>(៤៨,០០០រៀល)ក្នុង១ខែ | |
| ១០ឆ្នាំ | ១០,៧៥% | ១០/៣២-៩/៤២ | ៥,៣៧៥%<br>(៦៤,៥០០រៀល) ក្នុង១ខែ | ៥,៣៧៥%<br>(៦៤,៥០០រៀល) ក្នុង១ខែ | |
| ១០ឆ្នាំបន្ត | ១៣,៥% | ១០/៤២-៩/៥២ | ៦,៧៥%<br>(៨១,០០០រៀល)ក្នុង១ខែ | ៦,៧៥%<br>(៨១,០០០រៀល)ក្នុង១ខែ | |
| ១០ឆ្នាំបន្ត | ១៦,២៥% | ១០/៥២-៩/៦២ | ៨,១២៥%<br>(៩៧,៥០០រៀល)ក្នុង១ខែ | ៨,១២៥%<br>(៩៧,៥០០រៀល)ក្នុង១ខែ | |

**រៀងរាល់១០ឆ្នាំ អត្រាភាគទានបូកបន្ថែម២,៧៥%**



បសស

# ៣.សោធនជរាភាព(ប្រាក់ចូលនិវត្តន៍ឬប្រាក់រំលែក)

**<u>លក្ខខណ្ឌ</u>**

- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- បានបង់ភាគទានយ៉ាងតិច១២ខែ
- មានអាយុយ៉ាងតិច៦០ឆ្នាំ

**<u>អត្ថប្រយោជន៍(តាមការលិក)</u>**

១.ទទួលបានប្រាក់សោធនប្រចាំខែ(១ខែបើក២ដង)

២.ទទួលបានសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ

**<u>ដោយឡែក</u>**

ករណីសមាជិក ប.ស.ស. បង់ភាគទានតិចជាង១២ ប.ស.ស.នឹងបើកប្រាក់ភាគទានដែលបង់សរុបបើកផ្តាច់តែម្តង (ទទួលបានវិភាជន៍ជរាភាព)

**<u>ការគណនាប្រាក់សោធន/ប្រាក់ចូលនិវត្តន៍/ប្រាក់រំលែក</u>**

ដើម្បីគណនាប្រាក់ចូលនិវត្តន៍ = អត្រាប្រាក់សោធនដែលបានបង់ x ប្រាក់ឈ្នួលមធ្យមដែលបានបង់ភាគទាន

ឧទាហរណ៍៖ ករណីសមាជិកបានបង់ភាគទាន ២០ ឆ្នាំ និងមានប្រាក់ឈ្នួលជាប់ភាគទាន ចំនួន ១,២០០,០០០រៀល

ប្រាក់ចូលនិវត្តន៍ដែលត្រូវទទួលបាន = ៣២.៥០% x ១,២០០,០០០រៀល = ៣៩០,០០០រៀល

## ឧបសម្ព័ន្ធ

| ឆ្នាំ | អត្រាសោធន | រូបមន្ត |
|---|---|---|
| ១ | ១,៧៥% | ១×១,៧៥% |
| ២ | ៣,៥០% | ២×១,៧៥% |
| ៣ | ៥,២៥% | ៣×១,៧៥% |
| ៤ | ៧,០០% | ៤×១,៧៥% |
| ៥ | ៨,៧៥% | ៥×១,៧៥% |
| ៦ | ១០,៥០% | ៦×១,៧៥% |
| ៧ | ១២,២៥% | ៧×១,៧៥% |
| ៨ | ១៤,០០% | ៨×១,៧៥% |
| ៩ | ១៥,៧៥% | ៩×១,៧៥% |
| ១០ | ១៧,៥០% | ១០×១,៧៥% |
| ១១ | ១៩,២៥% | ១១×១,៧៥% |
| ១២ | ២១,០០% | ១២×១,៧៥% |
| ១៣ | ២២,៧៥% | ១៣×១,៧៥% |
| ១៤ | ២៤,៥០% | ១៤×១,៧៥% |
| ១៥ | ២៦,២៥% | ១៥×១,៧៥% |
| ១៦ | ២៧,៥០% | ១៥×១,៧៥%+១×១,២៥% |
| ១៧ | ២៨,៧៥% | ១៥×១,៧៥%+២×១,២៥% |
| ១៨ | ៣០,០០% | ១៥×១,៧៥%+៣×១,២៥% |
| ១៩ | ៣១,២៥% | ១៥×១,៧៥%+៤×១,២៥% |
| ២០ | ៣២,៥០% | ១៥×១,៧៥%+៥×១,២៥% |
| ២១ | ៣៣,៧៥% | ១៥×១,៧៥%+៦×១,២៥% |
| ២២ | ៣៥,០០% | ១៥×១,៧៥%+៧×១,២៥% |
| ២៣ | ៣៦,២៥% | ១៥×១,៧៥%+៨×១,២៥% |
| ២៤ | ៣៧,៥០% | ១៥×១,៧៥%+៩×១,២៥% |
| ២៥ | ៣៨,៧៥% | ១៥×១,៧៥%+១០×១,២៥% |
| ២៦ | ៤០,០០% | ១៥×១,៧៥%+១១×១,២៥% |
| ២៧ | ៤១,២៥% | ១៥×១,៧៥%+១២×១,២៥% |
| ២៨ | ៤២,៥០% | ១៥×១,៧៥%+១៣×១,២៥% |
| ២៩ | ៤៣,៧៥% | ១៥×១,៧៥%+១៤×១,២៥% |
| ៣០ | ៤៥,០០% | ១៥×១,៧៥%+១៥×១,២៥% |
| ៣១ | ៤៦,២៥% | ១៥×១,៧៥%+១៦×១,២៥% |
| ៣២ | ៤៧,៥០% | ១៥×១,៧៥%+១៧×១,២៥% |
| ៣៣ | ៤៨,៧៥% | ១៥×១,៧៥%+១៨×១,២៥% |
| ៣៤ | ៥០,០០% | ១៥×១,៧៥%+១៩×១,២៥% |
| ៣៥ | ៥១,២៥% | ១៥×១,៧៥%+២០×១,២៥% |
| ៣៦ | ៥២,៥០% | ១៥×១,៧៥%+២១×១,២៥% |
| ៣៧ | ៥៣,៧៥% | ១៥×១,៧៥%+២២×១,២៥% |
| ៣៨ | ៥៥,០០% | ១៥×១,៧៥%+២៣×១,២៥% |
| ៣៩ | ៥៦,២៥% | ១៥×១,៧៥%+២៤×១,២៥% |
| ៤០ | ៥៧,៥០% | ១៥×១,៧៥%+២៥×១,២៥% |
| ៤១ | ៥៨,៧៥% | ១៥×១,៧៥%+២៦×១,២៥% |
| ៤២ | ៦០,០០% | ១៥×១,៧៥%+២៧×១,២៥% |
| ៤៣ | ៦១,២៥% | ១៥×១,៧៥%+២៨×១,២៥% |
| ៤៤ | ៦២,៥០% | ១៥×១,៧៥%+២៩×១,២៥% |
| ៤៥ | ៦៣,៧៥% | ១៥×១,៧៥%+៣០×១,២៥% |
| ៤៦ | ៦៥,០០% | ១៥×១,៧៥%+៣១×១,២៥% |
| ៤៧ | ៦៦,២៥% | ១៥×១,៧៥%+៣២×១,២៥% |
| ៤៨ | ៦៧,៥០% | ១៥×១,៧៥%+៣៣×១,២៥% |
| ៤៩ | ៦៨,៧៥% | ១៥×១,៧៥%+៣៤×១,២៥% |
| ៥០ | ៧០,០០% | ១៥×១,៧៥%+៣៥×១,២៥% |

* អត្រាសមាច័យ ១,៧៥% នៃ ១៥ឆ្នាំភាគទានដំបូង
* អត្រាសមាច័យ ១,២៥% នៃឆ្នាំភាគទានបន្តបន្ទាប់

# ៤. សោធនទុព្វលភាព(ពេលធ្លាក់ខ្លួនឈឺឬគ្រោះថ្នាក់ធ្ងន់ធ្ងរ)

**ទុព្វលភាព៖** សំដៅដល់ការបាត់បង់សមត្ថភាពការងារ ដែលមិនបណ្ដាលមកពីហានិភ័យការងារ។ អាចត្រូវចាត់ទុកជាជនរងទុព្វលភាព លុះត្រាតែសមីជនជាសមាជិក ប.ស.ស. មានជំងឺឬរងភាពពិការនាំឲ្យអស់សមត្ថភាពរកប្រាក់ចំណូល ឬរកប្រាក់ចំណូលទាបជាងចំណូលដែរកំណត់ក្នុងខ្សែបន្ទាត់ភាពក្រីក្រ។

## លក្ខខណ្ឌ

- បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
- បានបង់ភាគទានយ៉ាងតិច ៦០ខែ មុនកាលបរិច្ឆេទទទួលរងទុព្វលភាព

## អត្ថប្រយោជន៍(តាមភាលិក)

១.ទទួលបានប្រាក់សោធនប្រចាំខែ(១ខែបើក២ដង)

២.ទទួលបានសេវាព្យាបាលនិងថៃទាំវេជ្ជសាស្ត្រ

៣. អាចទទួលបានប្រាក់ឧបត្ថម្ភសម្រាប់អ្នកថៃរក្សា

## ចំណាំ

ករណីសមាជិក ប.ស.ស. បង់ភាគទានតិចជាង៣០ឆ្នាំ សន្មត់ថាបង់បាន៣០ឆ្នាំ(អត្រាសោធន៤៥%)

**សោធនទុព្វលភាព** = ៤៥% x ១,២០០,០០០រៀល = ៥៤០,០០០ រៀល

ថៃមអ្នកថៃរក្សា៥០%នៃ៥៤០.០០០រៀល =២៧០,០០០រៀល

# ៥. វិភាជន៍បូជាសព(ប្រាក់បូជាសព) និងសោធនឧត្តរជីវី

| លក្ខខណ្ឌដើម្បីទទួលបានវិភាជន៍បូជាសព | |
|---|---|
| សោធនិកជរាភាព(អ្នកចូលនិវត្តន៍ស្លាប់) | សោធនិកទុព្វលភាព(អ្នកចូលនិវត្តន៍ស្លាប់) |
| វិភាជន៍បូជាសពផ្អែកប្រាក់សោធនត្រូវកំណត់ស្មើនឹង ៥ខែនៃប្រាក់សោធនចុងក្រោយរបស់សាមីខ្លួន ឬត្រូវកំណត់អប្បបរមាស្មើនឹង ***២,០០០,០០០រៀល)*** | |

| លក្ខខណ្ឌដើម្បីទទួលបានសោធនឧត្តរជីវី | |
|---|---|
| សោធនិកជរាភាពឬទុព្វលភាព(ទទួលមរណភាព) | សមាជិក ប.ស.ស. បានបង់ភាគទានផ្អែកប្រាក់សោធន យ៉ាងតិច៦០ខែ(ទទួលមរណភាព) |
| សោធនឧត្តរជីវី(អ្នកមានសិទ្ធិបន្តក្នុងគ្រួសាររបស់គាត់) មានដូចជា៖ ប្ដីឬប្រពន្ធ និងកូនក្នុងបន្ទុក ទទួលបានចំនួន ៤៥% នៃប្រាក់សោធនជរាភាព និងសោធន ទុព្វលភាពរបស់សាមីជន | |

# ៦.លក្ខខណ្ឌចូលរួមតាមរបបភាគទានដោយស្ម័គ្រចិត្ត

សមាជិក **ប.ស.ស.** អាចចូលរួមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តបានលុះត្រាតែស្ថិតក្នុងស្ថានភាពចំនួន៣៖

**ទី១.បាត់បង់ការងារមុនអាយុ៦០ឆ្នាំ (ឈប់សម្រាកពីការងារ)**

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២. បានបាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០ឆ្នាំ
៣. និងមានលទ្ធភាពបង់ភាគទានបន្ត

**ទី២. មានអាយុ៦០ឆ្នាំចង់បង់ភាគទានបន្ត**

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២. មានអាយុ៦០ឆ្នាំ មានបំណងចង់បង់ភាគទានបន្ត
៣. និងមានលទ្ធភាពបង់ភាគទានបន្ត

**ទី៣. មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន**

១. បានចុះបញ្ជីក្នុងផ្នែកប្រាក់សោធន
២. កំពុងធ្វើការ
៣. ប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន

# ឃ សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

## ឃ.១ យន្តការចុះបញ្ជិកា និងការប្រមូលភាគទាន



NSSF Enterprise Web APP



NSSF Enterprise APP

- បានបង្កើតមុខងារថ្មីគឺចេញបង្កាន់ដៃបញ្ជាក់ការបង់ភាគទានតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ប.ស.ស. ដោយស្វ័យប្រវត្តិ
- បានធ្វើកិច្ចសហការណ៍គ្រប់ក្រសួង ស្ថាប័ន ក្នុងការធ្វើបច្ចុប្បន្នភាពព័ត៌មានជូនមន្ត្រីសាធារណៈឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយបន្ថែមរូបថត និងខ្ទៅដៃ
- ពង្រឹងយន្តការ ការចុះបញ្ជីផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត កាន់តែមានភាពច្បាស់លាស់ កំណត់បានតាមប្រភេទក្រុមគោលដៅ និងតាមប្រភេទមុខរបរ ស្របតាមគណៈកម្មាធិការសម្របសម្រួលការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

# ស្នាក់ការកណ្តាល និងសាខា ប.ស.ស. តាមបណ្តាលខេត្ត/ខណ្ឌ





# សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

## ឃ.២ គម្រោងសាកល្បងម៉ាស៊ីនស្វ័យសេវាសម្រាប់កំណត់អត្តសញ្ញាណ

គម្រោងសាកល្បង អនុវត្តតាមមន្ទីរពេទ្យជាតិ

60-90 នាទី





30-45 នាទី







1-2 នាទី & ភ្នាក់ងារនៅចាំជួយ

15-30 វិនាទី



កាត់បន្ថយពេលវេលារង់ចាំកំណត់អត្តសញ្ញាណ
សិទ្ធិពេញលេញប្រើប្រាស់សេវាសុខាភិបាលក្នុងដែនសមាជិក

# ឃ សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត

## ឃ.២ គម្រោងសាកល្បងប្រព័ន្ធអធិការកិច្ច និងការិយាល័យចល័ត



គ្រប់សកម្មភាពអធិការកិច្ច ត្រូវបានកត់ត្រាដោយដៃ (ក្រដាស និងកុំព្យូទ័រ)






ឌីជីថលនីយកម្មនៃគ្រប់សកម្មភាពអធិការកិច្ច ដោយអធិការអាចជួយផ្ដល់សេវា ប.ស.ស. ទាំងអស់នៅនឹងកន្លែង៖

- ចាត់ចែង និងតាមដានការងារអធិការកិច្ច
- ធ្វើរបាយការណ៍អធិការកិច្ច
- បោះពុម្ពលិខិតដាក់កំហិត និងព្រមាន
- ជួយចុះបញ្ជី និងប្រមូលភាគទាន
- បោះពុម្ពអង្កេតហានិភ័យការងារ
- ជំរឿនសហគ្រាស គ្រឹះស្ថាន

8

# សូមអរគុណ Thanks!

បេឡាជាតិសន្តិសុខសង្គម |

ទីស្នាក់ការកណ្តាលនៅភូមិបន្លាស្អិត  សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

Website: www.nssf.gov.kh/ Facebook Page: facebook.com/nssfpage/

មជ្ឈមណ្ឌលផ្តល់ព័ត៌មាន: 1286/1297